ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣៨ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា

យោងសារាចរណែនាំលេខ០៥ សរ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំខួបអនុស្សាវរីយ៍លើកទី១៣៨ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៤ ក្រោមប្រធានបទ "**សហគ្រាសមួយជាសហគមន៍សុខសាន្តមួយ**" ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូន បងប្អូនកម្មករនិយោជិត និយោជក និងសាធារណជន ជ្រាបអំពីការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣៨ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា ដូចខាងក្រោម៖

- រោងចក្រ សហគ្រាសបានឈប់សម្រាក ដើម្បីចូលរួមអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣៨ នៃទិវាពលកម្មអន្តរជាតិ ក្នុងនោះ មានរោងចក្រចំនួន ៦៤ បានរៀបចំកម្មវិធីអបអរសាទរទិវាពលកម្មអន្តរជាតិ ១ ឧសភា
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី ខេត្ត បានធ្វើជាសេនាធិការជូនរដ្ឋបាល រាជធានី ខេត្ត ក្នុងការរៀបចំអបអរសាទរទិវាពលកម្មអន្តរជាតិ ១ ឧសភា ទៅតាមទីកន្លែង និងកម្មវិធីរៀងៗខ្លួន ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាល
- នៅព្រឹកថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៤ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ សេដ្ឋកិច្ចក្រៅប្រព័ន្ធ និងសមាគមបុគ្គលិកសិក្សា ចំនួន ៥ ១៨៧នាក់
- នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៤៖
  - **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានអញ្ជើញសំណេះសំណាលជាមួយមន្ត្រីរាជការ បុគ្គលិក កម្មករ និយោជិត នៅកំពង់ផែស្វយ័តខេត្តព្រះសីហនុ
  - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣៨ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា ដោយមានការចូលរួមពីតំណាងអង្គការអន្តរជាតិខាងការងារ (ILO) តំណាងនិយោជក តំណាងសហជីព និងតំណាងក្រសួង ស្ថាប័ន ចំនួន ៣៥២នាក់ នៅទីស្តីការក្រសួង ប្រកបដោយបរិយាកាសរីករាយ យោគយល់ និងទទួលបានផ្លែផ្កា គួរជាទីមោទនៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ១៩

- ថ្នាក់ដឹកនាំសហភាពសហជីពចំនួន ២៥ បានរៀបចំកម្មវិធីសំណេះសំណាល និងកម្មវិធីកម្សាន្តក្នុងឱកាសទិវាពលកម្មអន្តរជាតិ ១ ឧសភា ទៅតាមទីកន្លែង និងកម្មវិធីរៀងៗខ្លួន ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាល
- សហជីព សមាគម និងអង្គការសង្គមស៊ីវិល បានប្រមូលផ្តុំនៅកន្លែងនានា និងហែញត្តិទៅដាក់ជូនរដ្ឋសភា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ជារួម ការប្រារព្ធខួបអនុស្សាវរីយ៍លើកទី១៣៨ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា ឆ្នាំនេះ បានប្រព្រឹត្តទៅកាន់តែសកម្ម និងផុសផុល ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល គឺដោយសារកម្ពុជាមានសុខសន្តិភាព ស្ថិរភាព មានទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មករនិយោជិត និងនិយោជកកាន់តែល្អ និងមានយន្តការត្រីភាគី កាន់តែល្អប្រសើរក្នុងការជជែកគ្រប់គ្រងបញ្ហាប្រឈម ដោយឈរលើគោលការណ៍នីតិរដ្ឋ និងបច្ចេកទេស ព្រមទាំងមានការសហការបច្ចេកទេសជាមួយអង្គការអន្តរជាតិខាងការងារ (ILO)។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមបងប្អូនកម្មករនិយោជិត និយោជក និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៨រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៤